ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា
មន្ទីរអប់រំ យុវជន និងកីឡារាជធានីភ្នំពេញ
វិទ្យាល័យ ទួលទំពូង

# ចូលរួមអបអរសាទរទិវាអំណាន

## លើប្រធានបទ
## តម្លៃសកលរបស់ស្នាដៃអក្សរសិល្ប៍

# រឿងទុំទាវ

## ឆ្នាំ ២០១៨

ឈ្មោះ ឈាន ម៉ារ៉ាឌី ភេទ ប្រុស
ទីកន្លែងធ្វើការៈ វិទ្យាល័យទួលទំពូង
លេខទូរស័ព្ទៈ 073 80 82 80 / 081 80 82 80

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា
មន្ទីរអប់រំ យុវជន និងកីឡារាជធានីភ្នំពេញ
វិទ្យាល័យ ទួលទំពូង

## ប្រធានបទ: <<តម្លៃសកលរបស់ស្នាដៃអក្សរសិល្ប៍ រឿងទុំទាវ>>

**សេចក្តីផ្តើម:**

រឿងទុំទាវ ជាស្នាព្រះហស្តរបស់ព្រះបទុមត្ថេរសោម និពន្ធនៅឆ្នាំ ១៩១៥ ជាកំណាព្យ បទពាក្យប្រាំពីរ មានចំនួន ១០៥០ល្បះ ។ ក្នុងចំណោមបណ្តាស្នាដៃអក្សរសិល្ប៍បុរាណបែបខេមរនិយម មានតែរឿងទុំទាវនោះទេ ដែលមានឈ្មោះ ល្បីល្បាញជាងគេ។ រឿង ទុំទាវ គឺជាស្នាដៃអក្សរសិល្ប៍មួយដែលរក្សាព្រលឹងបាននៅក្នុងខឿនអក្សរសិល្ប៍ជាតិ ខ្មែរយើង។ ស្នាដៃនេះមានលក្ខណៈល្អទាំងផ្នែកអត្ថន័យ អត្ថរូប និងអត្ថរស ពោលគឺមិនចាញ់ស្នាដៃអក្សរសិល្ប៍ បស្ចឹមប្រទេសឡើយ។ ប្រជាជនខ្មែរគ្រប់ប្រទាប់វណ្ណៈគ្មាននរណាម្នាក់ដែលថា មិនស្គាល់រឿង ទុំទាវ នោះទេ ពេលខ្លះគេថែមទាំងបានលើកយកដំណើររឿង ឬ តួអង្គនៅក្នុងរឿងមកធ្វើជាឧទាហរណ៍ដើម្បីអប់រំទូន្មានប្រៀនប្រដៅគ្នាទៀតផង ។

ដោយសារប្រជាប្រិយភាពនៃរឿង ទុំទាវ បែបនេះឯង ទើបរឿងទុំទាវ ត្រូវបានក្រសួងអប់រំយុវជន និងកីឡាយកមកបញ្ចូលក្នុងកម្មវិធីសិក្សានាសាលាចំណោះទូទៅតាំងពីសម័យមុន រហូតដល់បច្ចុប្បន្ន។ រឿងទុំទាវ គឺជាស្នាដៃមួយមានតម្លៃសកល និងជាមរតកយ៉ាងសំខាន់សម្រាប់ខេមរាប្រុសស្រីគ្រប់ៗសម័យកាល។

**តើកត្តាអ្វីខ្លះដែលធ្វើឲ្យរឿងទុំទាវ មានតម្លៃសកលបែបនេះនៅក្នុងសង្គមខ្មែរយើង?**

កត្តាដែលធ្វើឲ្យស្នាដៃអក្សរសិល្ប៍រឿង ទុំទាវ មានតម្លៃសកលនៅក្នុងខឿនអក្សរសិល្ប៍ជាតិ និងសង្គមខ្មែរយើង ពីព្រោះ រឿងទុំទាវ បានទ្រទ្រង់នូវព្រលឹងជាច្រើនដូចជា៖

**១- ព្រលឹងវប្បធម៌ជាតិ**

ប្រទេសខ្មែរជាជង្រុកនៃវប្បធម៌ ។ បុព្វបុរសដូនតាខ្មែរសុទ្ធសឹងតែជាអ្នកប្រកបដោយគំនិតច្នៃប្រតិដ្ឋ លោកបានបន្សល់ទុកឲ្យកូនចៅខ្មែរជំនាន់ក្រោយនូវប្រពៃណី ទំនៀមទម្លាប់ ជំនឿ សាសនា និងផ្នត់គំនិតយ៉ាងសំបូរបែប ។ ជាតិសាសន៍មួយដែលគង់វង្សបានដរាបណាជាតិសាសន៍នោះរក្សាបានអត្តសញ្ញាណ នៃវប្បធម៌ជាតិខ្លួន យ៉ាងណាមិញរឿងទុំទាវក៏បានលើកយកអត្តសញ្ញាណនេះ ដែលខ្មែរមានតាំងពីមុនរហូតដល់បច្ចុប្បន្ន មកបង្ហាញ ស្របតាមចំណង់ចំណូលចិត្តខ្មែរមានជាអាទិ៍៖

១.១- ប្រពៃណី និងទំនៀមទម្លាប់

១.១.១- ប្រពៃណីគ្រមុំចូលម្លប់

ប្រពៃណីក្រមុំចូលម្លប់ ជាប្រពៃណីមួយដែលមិនទាន់រលុបបាត់ពីសង្គមខ្មែរនោះឡើយ ជាក់ស្តែងបច្ចុប្បន្ននេះ ប្រពៃណីក្រមុំចូលម្លប់នៅតែធ្វើជាប្រចាំនាស្រុកស្រែអំបិល ខេត្តកោះកុង ស្រុកសូទ្រនិគម ខេត្ត សៀមរាប និងស្រុកបាធាយ ខេត្តកំពង់ចាម។ ប្រពៃណីនេះតម្រូវឲ្យស្រីពេញក្រមុំចូលម្លប់ ដើម្បីរក្សាសម្ផស្ស ព្រមទាំងរៀនសូត្រធម៌អាថ៌ ច្បាប់ចរិយាធម៌ និងវិជ្ជាមេផ្ទះ ជាដើម។ នៅសម័យលង្វែកប្រពៃណីនេះបានអនុវត្តលើ នាងទាវ។ ដោយសារតែការចូលម្លប់ ទើបធ្វើឲ្យនាងទាវមានសម្រស់គួរជាទីគយគន់។ មិនត្រឹមតែប៉ុណ្ណោះនាង ទាវត្រូវបានជ្រើសជាកញ្ញាឯកនាសម័យលង្វែក ដើម្បីត្រៀមធ្វើស្នំព្រះរាជាផង ។

– ចាំទៅដល់ផ្ទះប្រាប់ទាវគ្រប់ ទាវនៅក្នុងម្លប់សមស្រណោះ
នាងជាម្តាយទាវមានរបស់ កូនស្រស់រូបស្រេចដាច់ស្រីផង ។

(ទំព័រ៩)

១.១.២- ទំនៀមទម្លាប់ " កូនប្រុសបួសរៀននៅតាមទីវត្តអារាម "

នៅសម័យបុរាណកូនប្រុសធំឡើងត្រូវតែបួសរៀន ព្រោះទីវត្តអារាមជាសាលាពហុបច្ចេកទេស។ អ្នកបួសពេលលាចាកសិក្ខាបទមកជាគ្រហស្ថ គេតែងតែនិយមហៅថាបណ្ឌិត។ អ្នកបួសចេះទាំងផ្លូវលោក និងផ្លូវធម៌ យ៉ាងណាមិញបណ្ឌិត ទុំ ពេជ្រចេះធ្វើគោក ចេះស្នូត្រ ចេះភ្លុំប៉ី ព្រមទាំងចេះធ្វើពាណិជ្ជកម្មផងដែរ ។ ដោយសារតែការបួសរៀនបណ្ឌិត ទុំ ពេជ្រ ត្រូវបានព្រះបាទរាមាតែងតាំងជាម៉ឺនឯកបម្រើការនៅក្នុងរាជវាំង ។

– កើតឡើងលុះធំល្មមប្រមាណ ឆ្នាំច្រើនសោតបានម្តាយគុបតែង
យកទៅឲ្យរៀនចោលគ្រឿងល្បែង ស្វះស្វែងនៅវត្តវិហារធំ ។
– លោកគ្រូទទួលស្រួលព្រះទ័យ ប្រឹកប្រៀនទុំវៃខាងអាគម
អាចគាប់ដោយប្រាជ្ញប្រឹងជញ្ជ្រាំ ខិតខំចង់បួសផ្នួសសាមណេរ ។

(ទំព័រ៥)

១.១.៣- ប្រពៃណីអាពាហ៍ពិពាហ៍

ប្រពៃណីរៀបអាពាហ៍ពិពាហ៍ គឺជាពិធីមួយផ្សំផ្គុំកូនប្រុសស្រីឲ្យក្លាយជាគូស្វាមីភរិយាស្របច្បាប់ទម្លាប់។ រឿងទុំទាវ បានលើកមកបង្ហាញពីប្រពៃណីអាពាហ៍ពិពាហ៍ខ្មែរដែលប្រព្រឹត្តទៅមានច្រើនដំណាក់កាល រួមមានពិធីចែចូវ ពិធីមើលឫក្សពារ ពេលា ថ្ងៃសាកសមរៀបអាពាហ៍ពិពាហ៍ជាដើម។ លើសពីនេះទៅទៀតពិធីនេះត្រូវរៀបចំនៅផ្ទះខាងស្រីជាចាំបាច់ យ៉ាងណាមិញមុនពេលរៀបការនាងទាវជាមួយម៉ឺនងួន ក្រុមគ្រួសារអរជូន បានឲ្យគេចូលចែចូវទាវ និងមើលឫក្សពារពេលាល្អផងដែរ ។

អធិប្បាយនិយាយខាងចែចូវ ជាអ្នកនាំផ្លូវតាមដូនតា
ឲ្យទៅស្រីដីខាងមេបា នាងទាវ តើថាប្រការម្តេច ។

(ទំព័រ៤៧)

ចាត់រកអាចារ្យខ្មែរធ្វើធ្មេញ អាចារ្យមួយដេញថ្ងៃជោគជា

បូក្សរួមខ្មើយខ្ពល់តម្កល់ពារ រូបរួមមូលគ្នាជាយូរទៅ ។

(ទំព័រ៩៧)

១.២- សាសនា

រឿងទុំទាវ បានលើកមកបង្ហាញពីសាសនាមួយដែលប្រជាជនខ្មែរជាងកៅសិបភាគរយគោរពបូជា នោះគឺព្រះពុទ្ធសាសនា។ ទោះបីនៅសម័យលង្វែក ប្រជាជនខ្មែរគោរពព្រះពុទ្ធសាសនានិកាយមហាយានក៏ដោយ ក៏ទ្រឹស្តីព្រះពុទ្ធសាសនានៅតែដក់ជាប់ក្នុងចិត្តគំនិតពុទ្ធសាសនិកជនតាំងពីពេលនោះរហូតដល់បច្ចុប្បន្ន។

ទាវផ្ទប់ឈប់អង្គផ្ទង់ស្មារតី បើកហត្ថទាំងទ្វីដាក់សិរសា

ប្រណម្យហើយមានវាចាថា ខ្ញុំសូមនមស្សការដល់ព្រះពុទ្ធ

ព្រះធម៌ព្រះសង្ឃអង្គអរហន្ត នៅក្នុងបច្ចុប្បន្នសូមចំហុត

អង្គឥន្ទ្រទេវិន្ទទាំងទេវបុត្ត សូមជួយឆាប់ផុតដូចសច្ចា ។

(ទំព័រ១០៧)

១.៣- ជំនឿ

គ្រប់ជាតិសាសន៍នៅលើលោកសុទ្ធតែមានជំនឿផ្ទាល់សម្រាប់ជាតិសាសន៍នីមួយៗ។ ជនជាតិខ្មែរក៏មានជំនឿផ្ទាល់ខ្លួនដែរ ជាក់ស្តែងជនជាតិខ្មែរជឿលើព្រលឹង អ្នកតា បារមីវត្ថុស័ក្តិសិទ្ធិ អព្ភូតហេតុ ហោរាជាដើម។ ក្នុងវិស័យជំនឿនេះ រឿងទុំទាវ បានបង្ហាញពីជំនឿរបស់ប្រជាជនខ្មែរជាច្រើនព្រមទាំងបានចាក់គ្រឹះយ៉ាងមាំនៅក្នុងសន្តានចិត្តជនជាតិខ្មែរគ្រប់ៗគ្នា។

១.៣.១- ជំនឿលើការទស្សន៍ទាយ ជឿលើហោរា

ជំនឿលើការទស្សន៍ទាយពុំទាន់សាបរលាបពីក្នុងស្រទាប់ប្រជាជនខ្មែរនោះទេ ជាក់ស្តែងនាពេលបច្ចុប្បន្ននេះ មុនបើកអាជីវកម្មក្តី រៀបការកូនប្រុសស្រីក្តី សង់ផ្ទះថ្មីក្តី ទិញរបស់របរផ្សេងៗដែលមានតម្លៃក្តី ប្រជាជនខ្មែរតែងតែទៅរកហោរាឲ្យជួយទស្សន៍ទាយដើម្បីមើលថា ទទួលយកបាន ឬមិនបាន និងយកថ្ងៃនេះល្អ ឬថ្ងៃនោះល្អជាដើម។ រឿងទុំទាវបានលើកមកបញ្ជាក់ពីឥទ្ធិពលនៃការទស្សន៍ទាយនេះយ៉ាងច្បាស់ជាក់ស្តែង ពេលទុំសុំលោកគ្រូលាចាកសិក្ខាបទ លោកគ្រូចៅអធិការវត្តវិហារធំបានទស្សន៍ទាយវាយលេខអត្ថៈមើលជើងលេខរបស់ទុំពោលគឺ ទុំពុំអាចសិកឆ្នាំនេះបានឡើយ ជើងលេខរបស់ទុំចំលើលេខតៃហោង ប៉ុន្តែទុំនៅតែជម្ទះសិកម្នាក់ឯងក្បែរដំបូក។ ទីបំផុតទុំត្រូវស្លាប់ដូចពាក្យគ្រូទាយមែនសមនឹងពាក្យខ្មែរថា " គ្រូទាយ ម្តាយថា" ដូច្នេះឯង ។

លោកគ្រូស្តាប់ជាក់កន្ត្រាក់ក្តារ- ឆ្នួនបូកលេខហារថាតៃហោង

កុហកអញទេអាកន្ទ្រម ស្រីចោមស្រូតចោលបោលមកលា ។
អញវាយលេខលុបគ្រប់ជើងហារ លេខឆ្លើយឡើងថាអាកុំពារ
កុំពុះទម្លុះក្រែងវេទនា ឃើញថានេនពេជ្រ គេចគ្រាន់បើ ។

(ទំព័រ២២)

### ១.៣.២- ជឿលើមន្តអាគមគាថា

តាំងពីសតវត្សទី១ រហូតមកដល់ចុងសម័យអង្គរ ប្រជាជនខ្មែរគោរពបូជាចំពោះសាសនាព្រាហ្មណ៍។ លុះចាប់ពីក្រោយសម័យអង្គរមកប្រជាជនខ្មែរគោរពព្រះពុទ្ធសាសនា ប៉ុន្តែឥទ្ធិពលសាសនាព្រាហ្មណ៍ក៏នៅមានលាយឡំជាមួយព្រះពុទ្ធសាសនាដដែល ដូចជាតាមរយៈមន្តអាគមស្តោះផ្លុំ ការធ្វើស្នេហ៍ស្នេក ការរៀបបាយសី ស្លាធម៌ដូង ការសែនក្រុងពាលី ។ល។ ចំពោះមន្តអាគមធ្វើស្នេហ៍បន្ទន់ចិត្តមានប្រភពចេញមកពីគម្ពីរអាថវវេទដែលផ្នែកមួយនៃគម្ពីរត្រៃវេទរបស់សាសនាព្រាហ្មណ៍។ ដើម្បីអោយលក់ដាច់ ឲ្យប្ដី ឬប្រពន្ធស្រឡាញ់ ប្រជាជនខ្មែរនៅតែមានផ្នត់គំនិតជឿលើមន្តអាគមធ្វើស្នេហ៍នេះ។ នៅពេលដែលទុំចាប់ចិត្តស្រឡាញ់នាងទាវដំបូង ហើយខ្លាចនាងទាវមិនស្រឡាញ់ខ្លួនវិញ ទុំបានសូត្រមន្តគាថាសារិការលិនចោងដាក់ស្នេហ៍នាងទាវ ។

នេនទុំទទួលគ្រឿងបរិក្ខារ ស្រេចស្រាយយកស្លាឆាន់រួចនៅ
ឈប់អង់បន្តិចសែកប្រេងម្សៅ រំលឹកដល់ទៅមន្តសារិកា ។
លិនចោងករវិករំលឹករក សម្ពិលីហៅយក មណីចិន្តា
លូកយកប្រទាលឆាន់នឹងស្លា សូត្រសារគ្រប់សព្វចប់ជាម្តង ។

(ទំព័រ១៤)

### ១.៣.៣- ជឿលើកម្មផល

ទ្រឹស្តីកម្មផល ជាទ្រឹស្តីនៅក្នុងព្រះពុទ្ធសាសនា ប៉ុន្តែក្រោយពីសម័យអង្គរមក ប្រទេសខ្មែរបានជួបប្រទះនូវសង្គ្រាមជាញឹកញាប់ រហូតស្ទើរតែបាក់ស្បាត ទើបជាហេតុធ្វើឲ្យប្រជាជនមានជំនឿផ្តេកផ្តួលទៅលើកម្មផលនេះ ដើម្បីបន្លប់នូវទុកសោក និងការលំបាកវេទនារបស់ខ្លួន។ នៅក្នុងរឿងទុំទាវបានបញ្ជាក់ថា ការស្លាប់របស់ទុំបណ្តាលមកពីកម្មដែលគាត់បានសាងពីជាតិមុន ពិសេស គឺមិនបានធ្វើទានរក្សាសីលតែម្តង ទើបកម្មឲ្យផលបែបនេះ ។

ជាកម្មអកុសលផ្តល់គាត់ហើយ ជនអើយចូលស្តាប់ចាប់ចាំបាន
យកទុកដាក់ខ្លួនពួនចេញថ្កាន ចៀសសង្សារសាន្តខានឃើញទុក្ខ ។
គួរយកធម៌អាថ៌ជាទីពឹង ពំនឹងសីលទានស្ពានទៅមុខ
សសៀរជៀសចាកផុតនរក កុំធ្វើឆោតឆុរនៅខ្លៅល្ងង់ ។

(ទំព័រ១០១)

១.៤- ផ្ទត់គំនិត

មាតាបិតាខ្មែររមែងប្រកាន់នូវផ្នត់គំនិត " ធំមិនធំជាងនាឡិ " មានន័យថា ទោះបីកូននោះមានអាយុចំណាស់ណា ឬកូននោះមានបុណ្យស័ក្តិធំប៉ុនណាក៏កូននៅតែជាកូនរបស់គាត់ ពោលគឺ កូនមិនអាចធំជាងឪពុកម្តាយបានឡើយ ប្រៀបបាននិងធំក៏មិនដែលជាងនាឡិដូច្នេះដែរ ។ ផ្នត់គំនិតនេះបានអនុវត្តន៍យ៉ាងតឹងរឹងចំពោះកូនដែលពេញវ័យរៀបការ ពិសេសចំពោះ រឿងរើសគូរស្រករប្រចាំជីវិត ។ មាតាបិតាខ្មែរទាំងឡាយដែលប្រកាន់នូវផ្នត់គំនិតនេះដោយមូលហេតុគាត់សំអាងថា គាត់ជាមនុស្សចាស់ ជាមនុស្សប្រកបដោយបទពិសោធន៍រឿងជីវិត ហើយការគិតរបស់គាត់បានវែងឆ្ងាយជាងកូនៗ និងក្មេងៗ ដែលទើបពេញវ័យ ។ ឪពុកម្តាយគ្រប់រូបសុទ្ធតែចង់អោយកូនមានបាន រស់នៅប្រកបដោយសុភមង្គល គ្មានមាតាបិតាណា អាចឈរមើលកូនរស់ក្នុងក្តីក្រីក្រលំបាកតោកយ៉ាកនោះឡើយ។ ម្តាយទាវ ក៏ដូចជាម្តាយដទៃទៀតដែរ គាត់បានប្រកាន់ខ្ជាប់នូវផ្នត់គំនិតនេះ។ គាត់មានតែបុត្រីទោលបណ្តូលចិត្តតែម្នាក់គត់ គាត់មិនចង់ឲ្យបុត្រីដែលមាន រូបសម្រស់ស្រស់ត្រកាលធ្លាក់លើដៃបុរសក្រខ្សត់ ខ្វាត់ព្រាត់ដែលមិនដឹងសារតារ និងពូជអំបូរដូចសុភាសិតខ្មែរ ពោលថា " ឈើកោងវល្លិ៍ព័ទ្ធ មនុស្សខ្វាត់ព្រាត់កុំយកខ្លួនបៀត " ។ ម្លោះហើយ គាត់ចង់លើកនាងទាវទៅឲ្យ ម៉ឺនងួន កូនលោក អរជូន ដែលនៅស្រុកភូមិជាមួយគ្នា ព្រោះគាត់បានស្គាល់ច្បាស់ពីសារបានពិតប្រាកដរបស់គ្រួសារនេះ ទោះបីនាងទាវប្រកែកមិនព្រមក៏ដោយក៏គង់អង្គរក្លាយជាបាយ នោះអ្វីៗនឹងត្រូវបានបញ្ចប់ដោយ រលូន ។

នែទាវទំនៀមព្រេងប្រៀបស្រាប់ ថាកូនមិនស្តាប់ចចេសរឹង
..ហាកយកទាញមករកសន្ទឹង របឹងរបាញសាញចណ្តាល ។
មិនដែលសោះឡើយទាវអើយនំ ច្រឡើសបើសធំម្តេចជាងនាឡិ
កូនគោកាចកៀចដោយព្រៃវាល ពោលពាលលើខ្លួនជូនដល់ស្លាប់ ។

(ទំព័រ៥០)

## ២- ព្រលឹងសង្គម និងបរិស្ថានធម្មជាតិ

ប្រជាជាតិខ្មែរជាប្រជាជាតិមួយដែលមានវ័យចំណាស់ជាងគេនៅក្នុងភូមិភាគអាស៊ីប៉ែកអាគ្នេយ៍នេះ។ ជនជាតិខ្មែរបានកសាងសង្គមជាតិស្របតាមធនធានធម្មជាតិរបស់ខ្លួន រហូតក្លាយជាចក្រភពអង្គរដ៏ល្បាញល្បីធ្វើឲ្យពិភពលោកស្ញើចសរសើរមិនដាច់ពីមាត់។ និរន្តរភាពនៃសង្គម វិសាលភាពធំទូលាយនៃទឹកដីនេះ មិនអាចកាត់ចេញបានពីការលះបង់របស់ព្រះមហាក្សត្រ និងប្រជារាស្ត្រខ្មែរនោះឡើយ ពោលគឺ ប្រៀបដូចជាទឹក និងត្រីដូច្នោះដែរ ។ រឿងទុំទាវបានលើកយកពីទិដ្ឋភាពសង្គម និងបរិស្ថានធម្មជាតិខ្មែរយ៉ាងសំបូរបែប ។ លក្ខណៈទាំងអស់នេះ ជាព្រលឹងជាតិខ្មែរដែលមានតាំងពីសម័យលង្វែករហូតមកដល់បច្ចុប្បន្ន។

## ២.១-. ព្រលឹងសង្គម

### ២.១.១- របបគ្រប់គ្រង

រឿងទុំទាវ បានបង្ហាញពីរបបគ្រប់គ្រងរបស់ខ្មែរនាសម័យលង្វែក គឺប្រកាន់របបរាជានិយម ដែលមានព្រះមហាក្សត្រជាអ្នកគ្រប់គ្រងជាតិ ។ ព្រះមហាក្សត្រជានិមិត្តរូបជាតិខ្មែរ ជាតំណាងអង្គយុត្តិធម៌ យ៉ាងណាមិញព្រះបាទរាមាក្នុងរឿងទុំទាវ គឺជាក្សត្រមានទសពិធរាជធម៌ ព្រះអង្គមិនសណ្ដោសចំពោះជនដែលបំពានច្បាប់ដូចអរជូននោះឡើយ។ ដោយសារតែការគោរពស្រឡាញ់អង្គព្រះមហាក្សត្រនេះហើយ ទើបរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ទី២ ជំពូកទី១ មាត្រា១ ចែងថា " ប្រទេសកម្ពុជា ជាព្រះរាជាណាចក្រ ដែលព្រះមហាក្សត្រទ្រង់ប្រតិបត្តិតាមរដ្ឋធម្មនុញ្ញ និងតាមលទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស " ។ ទាក់ទងនឹងការស្រឡាញ់ព្រះមហាក្សត្រនេះ ជនជាតិខ្មែរមានពាក្យទំនៀមថា " គ្រួសាររទីសរទាស ដូចរាស្ត្រអត់ស្ដេច " ។

| | |
|---|---|
| រីឯដំណើរអំបាលនេះ | នឹងបញ្ឈប់ស្នេះទុកសិនខ្សី |
| ថ្លាថ្លែងពីអង្គព្រះចក្រី | ស្ដេចគង់បុរីរដ្ឋរាជស្ថាន ។ |
| ស្ដេចគង់នគរកម្ពុជា | ឈ្មោះព្រះរាមារិទ្ធិថ្កើងថ្កាន |
| អស់រាស្ត្រប្រជាសី សុខសាន្ត | រាជស្ថានស្ដេចគង់បន្ទាយលង្វែក ។ |

(ទំព័រ៧៨)

| | |
|---|---|
| ទ្រង់ធម៌ថាអញយកទោសវា | សមនឹងឃ្លាតឃ្លាសង្សារសត្វ |
| ព្រះធម៌មេត្តានឹងបង់បាត់ | គួរជាត់ទាត់ចោលចេញទើបជា ។ |

(ទំព័រ៩៧)

### ២.១.២- មុខរបរប្រជាជន

ប្រជាជនខ្មែរជាង ៨០% ជាកសិករប្រកបរបរធ្វើស្រែចម្ការ ដើម្បីចិញ្ចឹមជីវិត ។ រឿងទុំទាវ បានលើកយកពីមុខរបរធ្វើស្រែចម្ការនេះមកបង្ហាញតាមរយៈតួអង្គទុំ ទើបជាបុព្វហេតុធ្វើឲ្យប្រជាជនខ្មែរភាគច្រើនជាកសិករមានការគាំទ្រពេញទំហឹង។ ក្រៅពីប្រកបមុខរបរធ្វើស្រែចម្ការ នៅសម័យលង្វែកមានប្រកបមុខរបរធ្វើភោក និងការត្បាញរវៃជាលក្ខណៈគ្រួសារ ។

| | |
|---|---|
| ថ្លាថ្លែងសម្ដែងដើមឈ្មោះទុំ | នៅខេត្តបាភ្នំដែនដីស្រែ |
| កើតកបទំនៀមមានឪម៉ែ | ប៉ុន្តែហេតុត្បិតឥតសម្ដែង ។ |

(ទំព័រ៥)

### ២.១.៣- ទីកន្លែង

រឿងទុំទាវបានលើកយកទីកន្លែងដែលមានពិតនៅក្នុងស្រុកខ្មែរមកបរិយាយ។ គ្រាន់តែនិយាយឈ្មោះ រឿងទុំទាវ គេតែងនឹកឃើញទៅដល់សម័យលង្វែក ដើមពោធិ៍ជើងខាលនៅ ខេត្តត្បូងឃ្មុំ ស្រុកកំណើតនាងទាវ ។ ក្រៅពីនេះទៀតមានឈ្មោះ ភូមិ ឃុំ ស្រុក ខេត្ត របស់ខ្មែរដែលជនជាតិខ្មែរធ្លាប់ស្គាល់ទាំង អស់ជាក់

ស្តែង ជ្រោយចង្វារ ទួកមាស គងពិសី ស្រីសន្ធរ ព្រែកពោធិ៍ កងតាញឹង ។ល។ ពេលដែលប្រជាជនខ្មែរបាន អាន ឬស្តាប់រឿងនេះ រមែងនឹកស្រណោះស្រណោកដល់ស្រុកកំណើតរបស់ខ្លួន ជួនខ្លះរហូតដល់ហូរទឹកភ្នែក រហាមក៏មាន ។

ខ្លះចេញទៅទ្រាំងខេត្តខាងក្រោម កូមិកំពង់សោមបន្ទាយមាស
បាទីព្រែកប្បាសច្រឡាសស្ពាស នឿយហត់ឈប់សៀមសេះដំរី ។

(ទំព័រ៦៩)

### ២.១.៤- ឧបករណ៍ប្រើប្រាស់

ឧបករណ៍ប្រើប្រាស់ដែលប្រើនៅក្នុងរឿងទុំទាវ សុទ្ធតែជាឧបករណ៍ដែលមានជីវិតរស់នៅយ៉ាង ជិតស្និទ្ធនឹងជីវភាពប្រជាជនខ្មែរតាំងពីមុនរហូតដល់បច្ចុប្បន្ន មានដូចជា រទេះគោ តោក ដន្លាប់ ប៉ី សាដៀវ ជាហ៊ុម ក្អម ជាដើម។ ប្រជាជនខ្មែរនិយមប្រើប្រាស់រទេះគោជាមធ្យោបាយដឹកជញ្ជូនផង និងធ្វើដំណើរទៅកាន់ ទីនានាផង យ៉ាងណាមិញពេលទុំ និងពេជ្រ ទៅលក់តោក នេនទាំងពីរបានបររទេះពីបាភ្នំ ខេត្តព្រៃវែង រហូត ដល់ខេត្តត្បូងឃ្មុំ ។ ក្រៅពីនេះមានការប្រើទូក សេះ ដំរី ផងដែរ ។

នេនរៀបបម្រុងការុងបាយ បង្ការទៅឆ្ងាយផ្លូវគ្រាច់ចរ
ប្រឹងអូសរទេះមកបញ្ឈរ ដឹកគោទឹមបរចរចេញទៅ ។

(ទំព័រ៧)

## ២.២- ព្រលឹងនៃបរិស្ថានធម្មជាតិ

ប្រទេសកម្ពុជាមានទីតាំងភូមិសាស្ត្រ សណ្ឋានដីអំណោយផលពិសេសស្ថិតក្នុងតំបន់ត្រូពិចក្តៅ ហើយសើមជាហេតុធ្វើឲ្យមានការរីកលូតលាស់រុក្ខជាតិគ្រប់ប្រភេទសម្រាប់ជាជម្រកនៃសត្វព្រៃ។ ប្រទេសកម្ពុជា មានបឹង ស្ទឹង ទន្លេ ដែលសំបូរទៅដោយមច្ឆាជាតិ និងវារីជាតិយ៉ាងស្រស់ត្រកាល។ រឿងទុំទាវបានលើកមក ពិពណ៌នាពីបរិស្ថានធម្មជាតិ សត្វព្រៃ មច្ឆាជាតិគួរជាទីពិតពិលរមិលមើល ។

### ២.២.១- ព្រៃឈើ

ពេលទុំធ្វើដំណើរកាត់ព្រៃពីរនាក់ពេជ្រ ទុំបានរៀបរាប់ឈ្មោះរុក្ខជាតិជាច្រើនមុខ។ រុក្ខជាតិខ្លះថ្វី ត្បិតតែបាត់រូបរាង បាត់ឈ្មោះ តែរុក្ខជាតិខ្លះទៀតបន្តនិរន្តរភាពមកដល់សព្វថ្ងៃ ព្រមទាំងផ្តល់ជាប្រយោជន៍ដូច ជា ធ្វើជាឱសថ ធ្វើទូក សម្រាប់សំណង់ផ្ទះសម្បែង ជាដើម។ ដោយសារបរិស្ថានព្រៃឈើនេះឯងធ្វើឲ្យអ្នកអាន មានជំនក់អារម្មណ៍។

មើលមានជ្រៃជ្រេសង្កែថ្កាន់ ត្រៀលគ្រស់ក្រវ៉ាន់គុយស្រគំ
ស្រឡីស្រឡៅពោធិ៍ក្ដុម្ភ ទ្រនំអាអូដ្ឋចង្ហួរត្នាត ។
ដង្កោទ្រយឹងខ្ទឹងក្រសាំង អំពិលភ្លូងភ្លាំងទាំងភ្លូតបាត

គូលេន ទុរេន មៀនលាំងសាត          មាក់បាតបង្គោញ្ញោចាន់ចារ ។

(ទំព័រ៦១)

២.២.២- សត្វវិទ្យា

បក្សាបក្សី ម្រឹគីម្រឹគា សត្វចតុបាទ តូចធំ គឺជាទីលម្អនៃព្រៃព្រឹក្សា រីឯមច្ឆាជាទីលម្អនៃជលស័យ។ រឿងទុំទាវបានលើកបង្ហាញពីប្រភេទសត្វល្អបជាច្រើន ហើយសត្វទាំងអស់នេះមិនទាន់ផុតពូជនៅឡើយ។

ដើរដោយព្រៃជ្រងរំលងជ្រៅ          ទទាហើរទៅទំទឹមគ្នា

ត្រសិតត្រសងហើររេរា          សេកនាំគូវាសសៀរទំ ។

(ទំព័រ៦៣)

២.២.៣- មច្ឆាជាតិ

ប្រទេសកម្ពុជា " ទីណាមានទឹក ទីនោះមានត្រី " រឿងទុំទាវ បានរៀបរាប់ពីហ្វូងមច្ឆាជាតិយ៉ាងច្រើន។ ត្រីបានផ្តល់ជាម្ហូបអាហារចាំបាច់សម្រាប់ការរស់នៅរបស់ប្រជាជនខ្មែរគ្រប់ស្រទាប់មិនថាអ្នកទីក្រុង ឬជនបទ ស្រុកស្រែចម្ការឡើយ។

សណ្តាយក្រុសក្រាយឆ្កិនច្រកែង          ផ្ទក់ក្រាញ់អណ្តែងច្រើនក្រាស់ក្រៃល

សរសៃកំពតផ្សោតប្រមៃល          ផុសផែលផុលផុងក្នុងគង្គា ។

(ទំព័រ៦៦)

៣- ព្រលឹងមនុស្សនិយម

មនុស្សគ្រប់រូបនៅលើភពផែនដីនេះ ទោះបី ស ខ្មៅ ខ្ពស់ ទាប ពិការ ខ្វាក់ខ្វិនខ្វង ថ្លង់គរ ក៏ដោយ ក៏អ្នកទាំងនោះសុទ្ធតែមានសារជាតិជាមនុស្ស។ សារជាតិជាមនុស្សរមែងមានតម្រូវការដូចៗគ្នាទាំងផ្នែកសម្ភារៈ ស្មារតី និងសិទ្ធិសេរីភាព។ រឿងទុំទាវជារឿងដែលមានលក្ខណៈមនុស្សនិយម ហើយលក្ខណៈមនុស្សនិយមនេះស្ថិតនៅត្រង់៖

៣.១- សិទ្ធិសេរីភាព

មនុស្សមានសិទ្ធិធំបីពីកំណើតគឺ សិទ្ធិមានជីវិត សិទ្ធិមានសេរីភាព និងសិទ្ធិទទួលបានសុភមង្គល។ នៅក្នុងកតិកាសញ្ញា និងអនុសញ្ញា ស្តីពីសិទ្ធិមនុស្សបានចែងយ៉ាងច្បាស់ថា មនុស្សទាំងអស់សុទ្ធតែមានសិទ្ធិសេរីភាពស្មើៗគ្នា។ សិទ្ធិសេរីភាពក្នុងទីនេះផ្តោតជាសំខាន់ទៅលើសិទ្ធិសេរីភាពក្នុងការជ្រើសរើសគូស្រករនេះឯង។ ទុំ និងទាវ ជាយុវជនដែលមានទស្សនៈ ជឿនលឿន បើប្រៀបធៀបនឹងយុវជនដទៃទៀតនាសម័យនោះ។ ស្ថិតក្នុងយុវវ័យដែលត្រូវកសាងជីវិតគ្រួសារ នាងទាវក៏មិនខុសពីនារីដទៃទៀតដែរ រមែងចង់បានបុរសដែលខ្លួនស្រឡាញ់មកធ្វើជាគូគាប់អនាគតសមដូចពាក្យខ្មែរយើងពោលថា " សង់ផ្ទះតម្រូវចិត្តអ្នកនៅ សង់ផ្លូវតម្រូវចិត្តអ្នកដើរ " ផ្ទុយទៅវិញមជ្ឈដ្ឋានសង្គមនាសម័យនោះកៀបសង្កត់បំបិទសិទ្ធិសេរីភាពនាងសព្វបែបយ៉ាងទាំងអស់

តាំងពីឬកពា អកប្បកិរិយា ពាក្យសម្ដី មនោសញ្ចេតនា ពិសេសនាងស្ថិតនៅក្នុងទ្រុងមួយយ៉ាងចង្អៀត គឺនាងនៅក្នុងម្លប់។ នៅពេលដែលនាងចេញពីម្លប់ម្ដាយនាងបានប្រើអំណាចផ្ដាច់ការបង្ខំនាងអោយរៀបការជាមួយម៉ឺនងួន ដោយយកទស្សនៈ " នំមិនធំជាងនាឡិ " និង " ពងមាន់កុំជល់នឹងថ្ម " មកគម្រាមកំហែង ។ ទោះយ៉ាងណាក៏ដោយក៏នាងនៅតែប្រឆាំងដាច់ខាត ស៊ូស្លាប់ប្រសិនណាមិនជួបទុំទេនោះ។ ការប្រឆាំងរបស់នាងទាវនេះគឺក្នុងគោលបំណងតែមួយគត់ គឺទាមទារសិទ្ធិសេរីភាពជ្រើសរើសគូស្រករ ។

បើម៉ែកែឲ្យកូនមានប្ដី    ទុំហ្នឹងដូចក្ដីស្និទ្ធស្នេហា
នេះកូនក៏ព្រមល្មមស្នេហា    ផ្ទាប់ផ្ទាល់រក្សាគ្នាតទៅ ។
ថាបើម៉ែមិនមានមេត្តា    ឲ្យខ្ញុំព្រមការម៉ឺនងួននៅ
សមក្ស័យជីវិតត្បិតមិនត្រូវ    អង្វរម៉ែឪសុំប្រកែក ។

(ទំព័រ៨៤)

### ៣.២- ស្នេហា

ស្នេហាជាបញ្ហាមួយដ៏សំខាន់សម្រាប់មនុស្ស សត្វដែលមានជីវិតរស់នៅ។ ចំពោះបញ្ហាស្នេហានេះ ទោះមនុស្សក្ដី សត្វក្ដី គឺគ្មានកំហុសទេ ព្រោះស្នេហាជាច្បាប់ និងជាក្រិត្យក្រមធម្មជាតិដែលពុំអាចគេចផុតបានឡើយ។ ស្នេហាជាទឹកដមជីវិត។ ស្នេហាធ្វើឲ្យមនុស្សមានសង្ឃឹមជានិច្ច។ ស្នេហាធ្វើឲ្យមនុស្សផុតពីភាពឯកោនៅលើពិភពគ្រោតគ្រាតដ៏ល្វីងល្វើនេះ។ ស្នេហាមិនប្រកាន់មានក្រ អាយុ ឬ ពូជសាសន៍ឡើយ។ នៅក្នុងបរិបទនេះ ទុំពេញកំលោះ ឯនាងទាវពេញក្រមុំ អ្នកទាំងពីរត្រូវតែមានស្នេហាដូចកម្លោះក្រមុំដទៃទៀតដែរ។ ថ្វីត្បិតតែអ្នកទាំងពីរស្ថិតក្នុងមជ្ឈដ្ឋានពីរផ្សេងគ្នាក៏ដោយ ក៏ស្នេហាទុំទាវជាស្នេហាកម្លោះក្រមុំប្រកបដោយភាពបរិសុទ្ធ គ្មានលាយឡំជាមួយទ្រព្យសម្បត្តិ លុយកាក់ បុណ្យស័ក្តិនោះឡើយ ពោលគឺ ស្នេហាអ្នកទាំងពីរកើតឡើងពីការប៉ះទង្គិចដោយក្រសែភ្នែកដែលមានអារម្មណ៍ជិតដាមដោយតណ្ហា។ ទុំ និងទាវ គ្រាន់តែឃើញគ្នាក៏ស្រឡាញ់គ្នាទៅវិញទៅមកយ៉ាងឆាប់រហ័ស។

អើតអើមដកកច្រហមាត់    ចង់ចេញប្រាកដគ្មានគេហៅ
ស្លុតស្លឹងម្នាក់ឯងដោយក្មេងសាវ    ស្ទុះចូលយកអាវពាក់ពានា ។
នេនយល់ដូច្នោះក្នុងពោះព្រួច    កាន់កួចកើតទុកចុកឱរា
ឱរូបហ្នឹងហើយទាវពុំងា    មិនងាកបំពាបំពេរន ។

(ទំព័រ១២)

### ៣.៣- ភក្ដីភាពរបស់ស្ត្រី

ភក្ដីភាព គឺជាព្រលឹងមួយដ៏សំខាន់របស់ស្ត្រីខ្មែរ ព្រោះថាស្ត្រីខ្មែរខុសពីស្ត្រីអឺរ៉ុប។ ស្ត្រីខ្មែរនិយមខ្លឹមកាយ ស្ត្រីអឺរ៉ុបនិយមខ្លឹមចិត្ត។ តាមឯកសារសិលាចារឹកខ្លះបានបញ្ជាក់ថា នៅសម័យអង្គរព្រះនាងជ័យរាជទេវី

ក្តី ព្រះនាងឥន្ទ្រទេវីក្តី ពេលព្រះបាទជ័យវរ្ម័នទី៧ ចេញទៅសមរភូមិប្រយុទ្ធជាមួយសត្រូវ ព្រះនាងទាំងពីរមែង សង្រួមចិត្តកាយឥន្ទ្រីយ៍ដោយការធ្វើសមាធិ ដើម្បីបញ្ជាក់ពីទឹកព្រះទ័យស្វាមីភក្តិ និងភក្តីភាពរបស់ខ្លួនចំពោះ ស្វាមី។ នាងទាវក៏ជាស្ត្រីមួយរូបមានទឹកចិត្តភក្តីភាពចំពោះទុំ តែម្នាក់គត់ កុំថាម៉ឺនងួន សូម្បីតែព្រះបាទរាមា ដែលជាស្តេចផែនដីក៏នាងពុំព្រមស្រឡាញ់។ នៅពេលដែលដឹងថា ទុំជាស្វាមីនាងត្រូវគេសម្លាប់ នាងទាវក៏សុខ ចិត្តស្លាប់តាមដែរ ដើម្បីថែរក្សាភក្តីភាពរបស់ខ្លួនជូនស្វាមី។

ប្រុសយកប្រឹថពីជាពូកខ្នើយ ទុំអើយប្រុសយកពពកខ្មី
បាំងជាពិតានស្មសានព្រៃ ត្រឈឹងត្រឈៃព្រលឹងប្អូន។
ទុំអើយម្ល៉េះហើយទាវមិនរស់ សូវស្លាប់តាមប្រុសឲ្យស្មោះសូន្យ
ម្តាយឥតមេត្តាករុណាកូន មិនដោយដំបូន្មានប្រដៅ ។

(ទំព័រ១០៧)

### ៣.៤- ស្នេហាពិតស្ថិតនៅលើចិត្ត និងចិត្ត

ស្នេហាទុំ និងទាវ កើតឡើងដោយចិត្ត និងចិត្ត គ្មានលាយឡំនិងឥទ្ធិពលអ្វីឡើយ ព្រោះថា នាងទាវ បាក់ចិត្តស្រឡាញ់ទុំក្នុងពេលដែលទុំស្ថិតក្នុងភេទជាព្រះសង្ឃ ដោយគ្មានអំណាច លុយកាក់ បុណ្យស័ក្តិ អ្វីទាំង អស់ ឯទុំវិញស្រឡាញ់ទាវក៏ពុំបានសម្លឹងឃើញទ្រព្យសម្បត្តិនាងទាវនោះដែរ។ អ្នកទាំងពីរស្រឡាញ់គ្នាប្តូរផ្តាច់ ស្លាប់រស់ជាមួយគ្នា ក្រោយពីអ្នកទាំងពីរស្គាល់ចិត្តថ្លើមគ្នាច្បាស់មក។ លើសពីនេះទៅទៀតអ្នកទាំងពីរប្រាថ្នា ជួបប្រមស្នេហាគ្នាគ្រប់ៗជាតិ។

ខ្លាចព្រះចេស្តាម្ចាស់ទ្រង់រិទ្ធិ ទូលបង្គំសូមពិតឯទាវហ្នឹង
ជាក់ជាសង្ស័យប្រាថ្នាពឹង សន្មត់វិលវឹងគ្រប់ជាតិ ។
ជាតិតាំងកំណត់សន្មត់កើត យោនយកកំណើតជាប្រុសស្រី
ឲ្យជួបទាវស្ងួននួនពិសី ប្រាថ្នាកុំបីឲ្យឃ្លាតឃ្លា ។

(ទំព័រ៧៧)

## ៤- ព្រលឹងអប់រំសែភល និងយុត្តិធម៌

### ៤.១- ព្រលឹងអប់រំសែភល

រឿងទុំទាវមានតម្លៃអប់រំសកលមួយ គឺអប់រំមាតាបិតាគ្រប់រូប គ្រប់សម័យកាល មិនត្រូវប្រកាន់ គំនិតដូចម្តាយទាវ ព្រោះបើប្រកាន់គំនិតបែបនេះនឹងធ្វើឲ្យខាតបង់គ្រប់បែបយ៉ាង។ អប់រំយុវជនទាំងឡាយឲ្យ ចេះទាមទារសិទ្ធិសេរីភាពជ្រើសរើសគូស្រករ ពិសេសបើបង្កើតស្នេហាហើយ ត្រូវចេះថែរក្សា ការពារស្នេហា ឲ្យបានគង់វង្សលុះជីវិតអវសានរៀងៗខ្លួន។

### ៤.២- ព្រលឹងយុត្តិធម៌

" យុត្តិធម៌តែងឈ្នះលើអយុត្តិធម៌ " នេះគឺជាស្មារតីពិតនៃច្បាប់។ ទោះបីទុំទាវស្លាប់មែន ប៉ុន្តែយុត្តិធម៌នៅតែមានចំពោះរូបគេទាំងពីរនាក់។ ការកាត់ទោសអរជូន និងបក្សពួកបែបនេះពីសំណាក់ព្រះបាទរាមាពិតជាត្រឹមត្រូវណាស់ ព្រោះដើម្បីពង្រឹងច្បាប់ប្រទេសបាន ដរាបណាដាក់ទោសទណ្ឌកម្មមន្ត្រីដែលរំលោភច្បាប់ដូចអរជូន នេះជាភស្តុតាង។ ដោយឃើញយុត្តិធម៌មានពិតនេះឯង ទើបធ្វើឲ្យប្រជារាស្ត្រនៅតែមានក្ដីសង្ឃឹមក្នុងជីវិតនៃការរស់នៅ។

ទ្រង់ត្រាស់កំហែងថ្លែងឱង្ការ ត្រាស់ថាយមរាជអាចតម្រូវ
ជំនុំកាត់ទោសឲ្យត្រឹមត្រូវ ហើយហៅនគរបាលឆាប់ថ្វាត់ ។
នគរបាលបង្គំព្រះចក្រី ត្រាស់ឱ្យស្មុះភ្លាមទៅចែងចាត់
ធ្វើតាមទោសានុទោសសត្វ ត្រូវចាត់ជាត់មូលចូលរណ្ដៅ ។

(ទំព័រ១៣០)

## ៥- ព្រលឹងនៃសិល្បៈតែងនិពន្ធ

### ៥.១- សម្ផស្សជើងកាព្យ

រឿងទុំទាវសរសេរជាកំណាព្យបទពាក្យ៧ តាំងពីដើមដល់ចប់។ សម្ផស្សជើងកាព្យអនុវត្តបានត្រឹមត្រូវតាមក្បួនកាព្យបទពាក្យប្រាំពីរ ដោយគោរពចំនួនព្យាង្គ ចំណាប់ជួនច្បាស់លាស់។ មិនត្រឹមតែប៉ុណ្ណោះសោត កវីបានប្រើវិធីរណ្ដំស្រះ រណ្ដំព្យញ្ជនៈ ធ្វើឲ្យពិរោះរណ្ដំណែងណង ល្អងល្អាយ ដែលអាចខាបអន្ទងព្រលឹងអ្នកអាន អ្នកស្ដាប់បានគ្រប់ៗសម័យកាល។

កន្លង់ក្រឡឹងផ្កាក្រឡាញ់ ដូចខ្លួនអង្គអញគ្រាច់ដើររក
ពពេចពពូលហើរចូលជ្រក ដូចអង្គអញមកនៅរួមកាយ ។
គ្រលីងក្រលោងក្រលែងវែក ក្រឡុះហើរបែកគូហ្វូងហ្វាយ
ដូចបងបែកទាវថ្លៃឆោមឆាយ មកដល់ឋានអាយអង្គឯកា ។

(ទំព័រ៦២)

១- ① ② ③ ④ ⑤ ⑥ ⑦ ① ② ③ ④ ⑤ ⑥ ⑦
① ② ③ ④ ⑤ ⑥ ⑦ ① ② ③ ④ ⑤ ⑥ ⑦ ។
២- ① ② ③ ④ ⑤ ⑥ ⑦ ① ② ③ ④ ⑤ ⑥ ⑦
① ② ③ ④ ⑤ ⑥ ⑦ ① ② ③ ④ ⑤ ⑥ ⑦ ។

## ៥.២- រូបារម្មណ៍នៅក្នុងកំណាព្យ

ភិក្ខុសោមអាចចាត់ទុកជាកវីម្នាក់ដែលមានទេពកោសល្យប៉ិនប្រសប់ក្នុងការតែងកំណាព្យយ៉ាងល្អឆើត ដោយមិនចាញ់កវីនានានៅក្នុងប្រទេសកម្ពុជាយើងឡើយ។ ស្នាដៃកំណាព្យនៅក្នុងរឿងទុំទាវចំនួន ១០៥០ល្បះ បានបង្កើតនូវរូបភាពដែលមានលក្ខណៈ ឬ សកម្មភាពរស់រវើកនៅក្នុងអារម្មណ៍អ្នកអាន អ្នកស្ដាប់ តាមរយៈការប្រើពាក្យពេចន៍ ឃ្លោងឃ្លាយ៉ាងណែងណង។

### ៥.២.១- ឧបមាណរូបារម្មណ៍

ជារូបារម្មណ៍ដែលកើតមាននៅក្នុងឃ្លាប្រយោគដោយកវីសោមឧបមាវត្ថុមួយទៅនិងវត្ថុមួយទៀតដោយប្រើចំណងធៀប ។

ទាវថាខ្លួនប្អូនដូចតារា          ប្រុសថ្លៃស្នេហាដូចចន្ទ្រា
តារារះរាយលើមេឃា          អមអង្គចន្ទ្រាមិនមានឃ្លាត ។

(ទំព័រ៥៥)

### ៥.២.២- រូបារូប្បារម្មណ៍

គឺជារូបារម្មណ៍ជាច្រើនទៀតដែលកវី ងួន សោម បានប្រើប្រាស់នៅក្នុងកំណាព្យរឿងទុំទាវ ។

## ៩- ឥន្ទ្រីយ៍រូបារម្មណ៍

ជារូបារម្មណ៍ដែលកើតឡើងនៅក្នុងរឿងទុំទាវតាមរយៈព្រះបទុមត្ថេរសោម លើកយកឃ្លោងឃ្លាប្រយោគធ្វើឲ្យកើបដល់គ្រឿងវិញ្ញាណទាំងប្រាំ។

+ចក្ខុរូបារម្មណ៍ៈ ភ្នែកហាក់មើលឃើញរូបភាពពិតៗ

ទុក្ខម្នោទោម្នេញគ្នាញ់តុរឆាវ          កន្ត្រាក់បានដាវស្ទុះចូលជុំ
ចូលចាប់កាប់ចាក់ឥតជំនុំ          ចងទុំក្រញឹតស្លឹតស្លាបសេក ។

(ទំព័រ១០៤)

+សោតរូបារម្មណ៍ៈ ត្រចៀកហាក់ឮសូរសំឡេងពិតៗ

សម្លេងផ្អែមល្ហែមស្រួយពីរោះ          ស្ដាប់ទាំងកម្លោះចាស់មេម៉ាយ
ក្រមុំក្បូងឃ្មុំរត់ប្រញាយ          ប្រញាប់ចង់ស្ដាប់ស័ព្ទភាសា ។

(ទំព័រ៨)

+កាយរូបារម្មណ៍ៈ កាយហាក់ព្រឺខ្វាកៗ

ព្រះពាយផាយផាត់ស្ទាត់ត្រជាក់          រហើយដល់ធ្លាក់សន្ទើមស្រោក
ស្រប់ស្រស់ចុះចំប្រគ្រំជោក          ជាប់ជាំដើមធ្លកឱឡោកបេង ។

(ទំព័រ៤១)

+យានរូបារម្មណ៍: ច្រមុះហាក់ធុំក្លិន

ឱបងពិដោរផ្កាក្រវាន់ ដូចក្លិនទាវស្បាន់ពិពកាយា
ពិដោរថ្មីៗដូចក្លិនផ្កា ជាប់នៅជាយជាហ៊ុមក្រវាត់ ។

(ទំព័រ៦២)

+ជីវ្ហារូបារម្មណ៍: អណ្តាតហាក់បានភ្លក្សរសជាតិ

ស៊ីនំស៊ីបាយស៊ីសម្ល ស៊ីខស៊ីហុងវង់ផឹកស្រា
ចាស់ៗប្រុសស្រីស្តីរកគ្នា ថាយើងពេលពារវេលាណា ។

(ទំព័រ៩៨)

**ខ- ភាមរូបារម្មណ៍:** បង្ហាញពីស្នេហាផ្លូវភេទរវាងទុំ និងទាវ

ហ៊ានមកថើបថ្ពាល់ពាល់ដល់ដោះ ចិត្តគ្មានក្រែងសោះមិនខបចៃ
ទុំថាបើខុសសុំឲ្យថ្លៃ ស្រឡាញ់យូរថ្ងៃឥតឧបមា ។

.................................... ....................................

ទុំឱបបីបមថ្នមប្រទ្បែង ទាំងពីឥតក្រែងរួមមេត្រី
នៅក្នុងគ្រិះស្ថានក្សាន្តដូចក្តី ស្រស់ស្រីស្រួលស្រើបដោយតណ្ហា ។

(ទំព័រ៥៤)

**គ- វេទនារូបារម្មណ៍:** ករើធ្វើឲ្យមានទុក្ខសោកញាប់ញ័រ

ទុំឈឺធំធំងឿងងិតមុខ ឈាមចុកឆ្អល់សៀតក្តៅដូចស្រុស
ដូចស្រែកទឹកពេកណាធ្លាយពោះ សាច់សុសធ្លុះសាច់ដាច់សរសៃ ។

(ទំព័រ១០៥)

## សន្និដ្ឋាន

បន្ទាប់ពីសិក្សាវិភាគរួចមក យើងអាចសន្និដ្ឋានថា រឿងទុំទាវ គឺជាស្នាដៃមួយមានតម្លៃសកលយ៉ាងពិត សម្រាប់ខ្មែរគ្រប់សម័យកាល ហើយជាស្នាដៃតំណាងឲ្យព្រលឹងខ្មែរ។ លើសពីនេះទៅទៀត រឿងទុំទាវ គឺជាស្នាដៃដែលលេចធ្លោក្នុងខឿនអក្សរសិល្ប៍ខ្មែរ ដោយបានចាក់ឫសយ៉ាងជ្រៅទៅក្នុងផ្នត់គំនិត ប្រពៃណី ទំនៀមទម្លាប់ ជីវភាពក្នុងសង្គមខ្មែរ អស់ជាច្រើនសតវត្សមកហើយ ហើយក៏ជាស្នាដៃដែលស្ថិតក្នុងចំណោមស្នាដៃដ៏ល្បីៗនៅក្នុងភូមិភាគអាស៊ីអាគ្នេយ៍នេះ ។

តាមការវិភាគដ៏ខ្លីនេះពិតជាពុំអាចឲ្យយើងស្វែងយល់បានសព្វអន្លើពីអត្ថន័យ និងតម្លៃរបស់ស្នាដៃនេះអស់បានឡើយ ប៉ុន្តែក៏បានរួមចំណែកក្នុងការបង្ហាញទេពកោសល្យនៃបុព្វបុរសខ្មែរដែលខិតខំបង្កើតនូវស្នាដៃនេះឡើង ដើម្បីថែរក្សា និងលើកស្ទួយនូវវប្បធម៌ជាតិឲ្យកាន់តែរុងរឿង រួចត្រូវចាំថា៖

<<អក្សរសាស្ត្រខ្មែរ ខ្មែរគួរថែថួន ឲ្យបានខ្ជាប់ខ្ជួនគង់វង្សគត់មត់
ព្រោះអក្សរសាស្ត្រគោលជាតិប្រាកដ អក្សររលត់ជាតិក៏រលាយ>> ។

ឈ្មោះ **ឈាន ម៉ាក់ឌី** ភេទ ប្រុស
ទីកន្លែងធ្វើការៈ វិទ្យាល័យទួលទំពូង
លេខទូរស័ព្ទៈ 078 80 62 80 / 061 80 82 80

# ឯកសារពិគ្រោះ

១. វចនានុក្រមខ្មែរ បោះពុម្ពដោយពុទ្ធសាសនបណ្ឌិត្យ ឆ្នាំ ១៩៦៧

២. សិក្សាអត្ថបទ ភាគីទី១ ភាគីទី២ របស់លោក លាង ហាប់អាន ឆ្នាំ ១៩៦៦

៣. រឿងទុំទាវរបស់ព្រះបទុមត្ថេរ សោម និពន្ធនៅឆ្នាំ ១៩១៥ បោះពុម្ពផ្សាយដោយពុទ្ធសាសនបណ្ឌិត្យ នាឆ្នាំ ១៩៧១

៤. បទអត្ថាធិប្បាយ រឿងទុំទាវ និពន្ធដោយអ្នកស្រី យិន វ៉ានថា ឆ្នាំ ១៩៨៩

៥. កំណាព្យខ្មែរ ដោយលោក លី សុមុនី បោះពុម្ពផ្សាយដោយក្រសួងអប់រំ ឆ្នាំ ២០០២

៦. សិល្បៈតែងកំណាព្យរបស់លោក ពេជ្រ ទុំក្រវិល គ្មានឆ្នាំ

៧. អត្ថាធិប្បាយទស្សនៈវិជ្ជារបស់លោក ស សារ៉ុន ឆ្នាំ ១៩៧៤

៨. សិក្សាអត្ថបទរឿងទុំទាវ រាមកេរ្តិ៍របស់ក្រសួងអប់រំនៃសាធារណៈរដ្ឋប្រជាមានិតកម្ពុជា ។

៩. រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣

១០. សិក្សាវិភាគស្នាដៃរឿងទុំទាវរបស់ ណាន ម៉ារ៉ាឌី ឆ្នាំ ១៩៩៦ ។

១១. ដំណើរជីវិតមនុស្សខ្មែរ មើលតាមពិធីឆ្លងវ័យ របស់លោក អាំង ជូលាន, ព្រាប ចាន់ម៉ារ៉ា , ស៊ុន ចាន់ដឹប ឆ្នាំ ២០០៧ ។